**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ: ៧៣៧ ពណ.ណ ១៩៨

## ញត្តិគាំទ្រ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងពាណិជ្ជកម្ម បានតាមដានយ៉ាងយកចិត្តទុកដាក់នូវព្រឹត្តិការណ៍ដ៏មានសារៈសំខាន់បំផុតជាប្រវត្តិសាស្ត្រ នាព្រឹកថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៥ នៅវិមានសន្តិភាព ដោយលោកជំទាវ **Mereani Kelleti Vakasisikakala** តំណាងអង្គការសហប្រជាជាតិ បាននាំយកផែនទីUTM ខ្នាត១/១០០.០០០ ចំនួន១៨ផ្ទាំង ដែលតម្កល់នៅអង្គការសហប្រជាជាតិ មកប្រគល់ជូនរាជរដ្ឋាភិបាលកម្ពុជាតាមសំណើសុំខ្ចីរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយផែនទី ដែលរាជរដ្ឋាភិបាលកម្ពុជា បានកំពុងប្រើប្រាស់ក្នុងការកំណត់ព្រំដែន រវាងកម្ពុជា និងវៀតណាម។

ការផ្ទៀងផ្ទាត់ផែនទីនេះ បានប្រព្រឹត្តទៅប្រកបដោយតម្លាភាពដែលមានការចូលរួមពីគ្រប់ភាគីដែលពាក់ព័ន្ធរួមមាន៖ តំណាងក្រុមប្រឹក្សាធម្មនុញ្ញ តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តំណាងព្រឹទ្ធសភា តំណាងរដ្ឋសភា តំណាងរាជរដ្ឋាភិបាលកម្ពុជា តំណាងគណបក្សប្រជាជនកម្ពុជា តំណាងគណបក្សសង្គ្រោះជាតិ តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច និងតំណាងរាជបណ្ឌិតសភាកម្ពុជា ហើយលទ្ធផលនៃការផ្ទៀងផ្ទាត់ បានបង្ហាញឲ្យឃើញយ៉ាងជាក់ច្បាស់ដោយឥតប្រកែកបានថា ផែនទីដែលអង្គការសហប្រជាជាតិនាំមក និងផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងប្រើប្រាស់ គឺមានភាពដូចគ្នាទាំងស្រុង។

លទ្ធផលនៃការផ្ទៀងផ្ទាត់ បានបង្ហាញអំពីភាពត្រឹមត្រូវនៃផែនទី ដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រើប្រាស់បច្ចុប្បន្ន និងបង្ហាញឲ្យឃើញថាការចោទប្រកាន់ ពីសំណាក់អ្នកនយោបាយឱកាសនិយមមួយចំនួនមកលើរាជរដ្ឋាភិបាលកន្លងមក គឺជាទង្វើគ្មានទំនួលខុសត្រូវ ដោយមិនតម្កល់ឧត្តមគតិជាតិជាធំ និងក្នុងគោលបំណងបម្រើអាជីវកម្មនយោបាយរបស់ខ្លួនតែប៉ុណ្ណោះ។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងពាណិជ្ជកម្ម សូមប្រកាសគាំទ្រយ៉ាងឱឡារិកចំពោះលទ្ធផលនៃការផ្ទៀងផ្ទាត់ផែនទីនេះ និងគាំទ្រយ៉ាងម៉ឺងម៉ាត់ចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលតែងប្រកាន់ខ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុងឧត្តម ក្នុងកិច្ចការពារបូរណភាពទឹកដី ជាពិសេសចំពោះការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងដោយឈរលើគោលនយោបាយសន្តិភាព មិត្តភាព និងការអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះ ក៏សូមថ្កោលទោសចំពោះទង្វើរបស់ជនអគតិមួយចំនួនដែលតែងតែធ្វើការប្រឌិត និងចោទប្រកាន់មូលបង្កាច់នាពេលកន្លងមកលើ កិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ហើយសូមអំពាវនាវដល់សាធារណជននិងជនរួមជាតិទាំងអស់ ត្រូវទុកចិត្តលើរាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៥